**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.............................................................

# សុន្ទរកថារបស់ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជា ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍ លើកទី១០០ នៃទិវាអន្តរជាតិនារី៨មីនា

ថ្ងៃទី ២ ខែមីនា ឆ្នាំ២០១១

សូមគោរព

- លោកជំទាវទេសាភិបាលរង ជាទីគោរព
- គណៈអធិបតី ជាទីគោរព
- បងប្អូននារីទាំងអស់នៃធនាគារជាតិនៃកម្ពុជា ជាទីរាប់អាន និងជាទីមេត្រី

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានជួបជុំជាមួយបងប្អូននារីធនាគារជាតិនៃកម្ពុជា ដើម្បីចូលរួមអបអរសាទរខួបលើកទី១០០ នៃទិវាអន្តរជាតិនារី៨មីនា ។

គិតមកដល់ពេលនេះ ជ័យជំនះនៃការតស៊ូរបស់ស្ត្រីក្នុងការរំដោះខ្លួនចេញពីការរើសអើងនៅក្នុងសង្គមមានរយៈពេល១០០ឆ្នាំហើយដែលស្ទើរគ្រប់ប្រទេសនៅលើសកលលោកបានប្រារព្ធខួបអបអរសាទររំឭកឡើងវិញនូវជ័យជំនះនេះ ។ ការរំឭកអំពីការតស៊ូនិងជ័យជំនះនេះបានក្លាយទៅជាទិវាអន្តរជាតិនារីនៅលើសកលលោក ដែលត្រូវបានកំណត់យកថ្ងៃ៨មីនាជាថ្ងៃរំឭកការតស៊ូនេះ ហើយដែលប្រទេសកម្ពុជាយើងទម្លាប់ហៅថា "ទិវាសិទ្ធិនារី" ។

ចាប់ពីក្រោយថ្ងៃរំដោះ៧មករា ប្រទេសកម្ពុជាបានចូលរួមអបអរខួបអនុស្សាវរីយ៍នេះជារៀងរាល់ឆ្នាំ ហើយតែងតែលើកយកប្រធានបទផ្សេងៗទាក់ទងនឹងស្ត្រី សម្រាប់ពិភាក្សានៅក្នុងឱកាសប្រារព្ធខួបនេះ ។ សម្រាប់ឆ្នាំនេះ ទិវាអន្តរជាតិនារី៨មីនានៅប្រទេសកម្ពុជាត្រូវបានរៀបចំឡើងក្រោមប្រធានបទស្តីពី "យុវវ័យជួយស្ត្រី គឺជួយខ្លួនឯង និងសង្គមជាតិ" សម្រាប់ជាគោលគំនិតក្នុងការពិភាក្សា ក្នុងការជួយពង្រឹងការអប់រំចំពោះយុវវ័យនៅក្នុងសង្គម ក៏ដូចជា ដើម្បីជាស់តឿនយុវវ័យ កែលំអឥរិយាបថផ្តាំផ្ងរបស់យុវវ័យ ។ល។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា កម្ពុជា គឺជាប្រទេសមួយដែលចាត់ទុកនារីជាមាតានៃប្រទេសជាតិតាំងពីយូរលង់ណាស់មកហើយ ដូចដែលយើងតែងតែបានឮនូវពាក្យថា "មាតុភូមិ ឬមាតុប្រទេសកម្ពុជា" ជាដើម ដែលមានន័យថា "ស្ត្រីជាមាតានៃប្រទេសជាតិ" ហើយបច្ចុប្បន្ន យើងនៅតែទទួលស្គាល់ថាស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងអប់រំ ដូចសុភាសិតខ្មែរយើងនិយាយថា "ស៊ូស្លាប់ប៉ា កុំឲ្យស្លាប់មេ" ដែលបង្ហាញថា វត្តមានរបស់ម្តាយផ្តល់នូវភាពកក់ក្តៅដល់កូនៗនិងគ្រួសារទាំងមូល ។ ប្រទេសកម្ពុជាធ្លាប់មានប្រវត្តិសាស្ត្រល្បីល្បាញនៅក្នុងសម័យមហានគរ ដោយនៅសម័យនោះ ព្រះនាងលីវយី ជាមហាក្សត្រីយ៍នៃនគរគោកធ្លក និងជាមេដឹកនាំដ៏ពូកែ ដែលប្រជារាស្ត្របានគោរពបូជា និងជឿទុកចិត្តលើការដឹកនាំរបស់ព្រះនាង ។ ក្រោយមកទៀត យើងមាន ព្រះនាង ឥន្ទ្រទេវី ដែលជាកំពូលស្ត្រីដ៏ឈ្លាសវៃឥតគូផ្ទឹម និងមានកងទ័ពដ៏ក្លាហានដែលជានារី ។ លើសពីនេះទៀត នៅក្រោយថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ របបប្រល័យពូជសាសន៍បានបន្សល់ទុកនូវស្ត្រីមេម៉ាយជាច្រើន ដែលស្ត្រីទាំងនោះត្រូវដើរតួនាទីជាម្តាយផង និងជាឪពុកផង ក្នុងពេលតែមួយ និងជារៀមច្បង ដើម្បីតស៊ូនិងទទួលបន្ទុកចិញ្ចឹមបីបាច់កូនៗ និងបងប្អូនៗដែលកំព្រា ។

បើយើងក្រឡេកមើលនៅក្នុងវិស័យធនាគារវិញ ជាពិសេសសុំលើកយកតែចំណុចតូចមួយនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ យើងឃើញថា ស្ត្រីមានភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់ និងគ្រប់គ្រងបំណុលបានយ៉ាងល្អប្រសើរ ។ បើពិនិត្យមើលធនាគារជាតិនៃកម្ពុជាយើងវិញ ជាក់ស្តែងបានឃើញហើយ គឺយើងមានទេសាភិបាលរងពីររូប ជាស្ត្រី ដែលអង្គុយនៅអមសងខាងខ្ញុំនេះ និងមានថ្នាក់ដឹកនាំជាស្ត្រីជាច្រើនទៀត ដូចដែលលោកជំទាវទេសាភិបាលរង និងជាប្រធានគណៈកម្មការនារីធនាគារជាតិនៃកម្ពុជាបានលើកឡើងនៅក្នុងសុន្ទរកថាមុននេះ ។

លោកជំទាវ ឯកឧត្តម និងបងប្អូននារីទាំងអស់ ជាទីស្នេហា

ធនាគារជាតិនៃកម្ពុជាក៏ចូលរួមអបអរសាទរទិវាអន្តរជាតិ៨មីនានេះដែរ ដោយតែងតែប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំ ហើយនៅឆ្នាំនេះ ក៏ដូចជាឆ្នាំមុនៗដែរ ធនាគារជាតិនៃកម្ពុជានៅតែបន្តប្រពៃណីផ្តល់វត្ថុអនុស្សាវរីយ៍ជូនមន្ត្រីបុគ្គលិកនារីយើងទាំងអស់គ្នា ឆ្នាំនេះ យើងមានហូល និងអាវប៉ាក់ ដើម្បីជូនមន្ត្រីបុគ្គលិកនារីយើងដែលបានរួមចំណែកកសាងសមិទ្ធផលរបស់ធនាគារជាតិនៃកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់បងប្អូននារីធនាគារជាតិនៃកម្ពុជា និងចំពោះគណៈអធិបតី និងភ្ញៀវកិត្តិយសជាបុរស ដែលបានចូលរួមអបអរសាទរខួបទី១០០នៃទិវាអន្តរជាតិនារីឆ្នាំនេះ ។

ខ្ញុំសូមជូនពរ លោកជំទាវ ឯកឧត្តម ភ្ញៀវកិត្តិយស និងបងប្អូននារីទាំងអស់នៃធនាគារជាតិនៃកម្ពុជា សូមជួបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧